ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ២០៤២ អក.លខ

សេចក្តីប្រកាសព័ត៌មាន

អគ្គិសនីកម្ពុជា សូមធ្វើការបដិសេធ ការចុះផ្សាយរបស់កាសែតភ្នំពេញប៉ុស្ត៍ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ដែលបានសរសេរថា " Derailed dam angers EdC boss " ។

នេះមិនមែនជាលើកទីមួយទេដែលកាសែតនេះបានចុះផ្សាយខុសពីការពិត។ អគ្គនាយកអគ្គិសនីកម្ពុជាមិនដែលបានចុះទៅជួបកងទ័ពនៅខេត្តព្រះវិហារដូចការចុះផ្សាយនោះឡើយ ហើយការចុះផ្សាយថា គម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែងមានផែនការដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧នោះ ក៏កាន់តែគ្មានមូលដ្ឋានទាល់តែសោះ។ នេះជាការប្រឌិតទាំងស្រុងរបស់កាសែតភ្នំពេញប៉ុស្ត៍។ គម្រោងដែលរាជរដ្ឋាភិបាលបានផ្អាកនេះ មិនទាន់ទាំងបានបញ្ចប់ការសិក្សានោះផងទេ ហេតុអ្វីក៏មានមូលដ្ឋានផលិតអគ្គិសនីបាននៅឆ្នាំ២០១៧? ម្យ៉ាងវិញទៀត អគ្គិសនីកម្ពុជាបានដកការគិតគូរពីគម្រោងនេះ ១០០% បន្ទាប់ពីមានការប្រកាសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**ស្តីពីការផ្អាកការសិក្សាគម្រោងនោះរួចទៅហើយ។ លើសពីនេះទៀត កាសែតនេះអះអាងថា " អគ្គនាយកអគ្គិសនីកម្ពុជា និយាយថា ការពន្យាពេលអនុវត្តគម្រោងខាងលើ នឹងធ្វើឲ្យអគ្គិសនីកម្ពុជាមានការលំបាកក្នុងការសម្រេចផែនការបញ្ចុះថ្លៃអគ្គិសនីមុនឆ្នាំ២០២០"។ នេះជាការអះអាងគ្មានមូលដ្ឋានមួយទៀត ដោយហេតុថា ផែនការបញ្ចុះថ្លៃអគ្គិសនីពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ គ្មានពាក់ព័ន្ធជាមួយការអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងជាយអារ៉ែងឡើយ ព្រោះផែនការក្នុងវិស័យថាមពល គ្មានគិតពីគម្រោងនេះមុនឆ្នាំ២០២០ទាល់តែសោះ។

ការចុះផ្សាយគ្មានមូលដ្ឋានរបស់កាសែតភ្នំពេញប៉ុស្ត៍ គ្រាន់តែអាចបង្ហាញថា កាសែតនេះគ្មានលក្ខណៈអាជីព និងខ្វះការទទួលខុសត្រូវតែប៉ុណ្ណោះ។ ដែលការនេះជាការសោកស្តាយដ៏ធំបំផុតរបស់អគ្គិសនីកម្ពុជា។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៥

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨